**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ: ០០៣ សណន

# សេចក្តីណែនាំ
# ស្តីពី
# ការកំណត់លក្ខណៈសម្បត្តិ និងនីតិវិធី
# នៃការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិ

កន្លងមក **ក្រសួងមហាផ្ទៃ** បានខិតខំប្រឹងប្រែងយកចិត្តទុកដាក់អនុវត្តកម្មវិធីកំណែទម្រង់កងកម្លាំងនគរបាលជាតិជាបន្តបន្ទាប់ឲ្យបានស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលទៅតាមដំណាក់កាលនីមួយៗ ដោយក្នុងនោះបានធ្វើទំនើបកម្មរចនាសម្ព័ន្ធ និងកែសម្រួលតួនាទីភារកិច្ច ព្រមទាំងបានកំណត់នូវលក្ខណៈសម្បត្តិ និងណែនាំនូវនីតិវិធីសម្រាប់ការងារតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិជាបន្តបន្ទាប់ ។

ក្នុងស្ថានភាពបច្ចុប្បន្ននេះ ដើម្បីពង្រឹងការងារតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិឲ្យកាន់តែល្អប្រសើរថែមទៀត សំដៅបង្កើនប្រសិទ្ធភាពក្នុងកិច្ចប្រតិបត្តិការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម **ក្រសួងមហាផ្ទៃ** ធ្វើការណែនាំអំពីការកំណត់លក្ខណៈសម្បត្តិ និងនីតិវិធីក្នុងការពិនិត្យវាយតម្លៃសម្រាប់ការស្នើសុំតែងតាំងមុខតំណែងជូនដល់មន្ត្រីនគរបាលជាតិទាំងពីរភេទ ដូចខាងក្រោម ៖

**ក- លក្ខណៈសម្បត្តិសម្រាប់ពិនិត្យក្នុងការស្នើសុំតែងតាំងមុខតំណែង :**

១- មានមនសិការស្នេហាជាតិ ស្មោះត្រង់ និងមានភក្តីភាពចំពោះ ជាតិ សាសនា ព្រះមហាក្សត្រ ។

២- គោរព និងប្រតិបត្តិបានម៉ឺងម៉ាត់នូវរាល់បទបញ្ជាផ្ទៃក្នុង គោលនយោបាយ និងច្បាប់របស់រដ្ឋ ។

៣- មានគំនិតផ្តួចផ្តើមច្នៃប្រឌិត មុខជំនាញវិជ្ជាជីវៈច្បាស់លាស់ ឧស្សាហ៍ព្យាយាម សកម្មការងារ និងមានស្មារតីទទួលខុសត្រូវខ្ពស់ ព្រមទាំងមានបទពិសោធន៍ល្អ ។

៤- មានសីលធម៌រស់នៅស្អាតស្អំ មិនប្រព្រឹត្តអំពើដែលបណ្តាលឲ្យប៉ះពាល់ដល់កិត្យានុភាពអង្គភាព និងកិត្តិយសរបស់ជាតិ ។

៥- មានសាមគ្គីភាពល្អ ទំនាក់ទំនងទូលំទូលាយជាមួយមន្ត្រីរួមការងារ និងសមត្ថកិច្ចពាក់ព័ន្ធចេះកៀរគរកម្លាំងសាធារណៈចូលរួមសហការបំពេញភារកិច្ចសម្រេចបានលទ្ធផលល្អ ។

៦- ជាសេវាបម្រើ ជាអ្នកការពារដ៏ស្មោះត្រង់ និងទទួលបានទំនុកចិត្តពីអង្គភាព និងប្រជាពលរដ្ឋ ។

៧- មានសមត្ថភាពគ្រប់គ្រងបញ្ជាដឹកនាំ និងបំពេញភារកិច្ចប្រកបដោយប្រសិទ្ធភាព មានការគាំទ្រគោរពស្រឡាញ់ជឿទុកចិត្តពីមន្ត្រីក្រោមឱវាទ និងប្រជាពលរដ្ឋ ។

៨- មានសុខភាពល្អ និងកាយសម្បទាមាំមួន ។

៩- បានឆ្លងកាត់វគ្គបណ្តុះបណ្តាលជំនាញនគរបាលជាតិយ៉ាងតិចពីរខែកន្លះឡើង ។ .

**ខ- នីតិវិធីនៃការតែងតាំងមុខតំណែង :**

រាល់ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិត្រូវអនុវត្តឲ្យបានត្រឹមត្រូវតាមរបៀបរបបការងារ គោលការណ៍ លក្ខណៈសម្បត្តិនៃការតែងតាំង និងត្រូវបំពេញបែបបទដូចខាងក្រោម ៖

១- សំណើរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានសាមី ថ្នាក់ប្រហាក់ប្រហែល ប្រធាននាយកដ្ឋាន-អង្គភាព និងស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត តាមឋានានុក្រម ។

២- កំណត់ហេតុប្រជុំពិភាក្សាវាយតម្លៃរបស់ថ្នាក់ដឹកនាំអង្គភាពដែលមានសមត្ថកិច្ចទៅលើលក្ខណៈ សម្បត្តិដូចបានកំណត់ខាងលើ ។

៣- ប្រវត្តិរូបសង្ខេបរបស់មន្ត្រីនគរបាលជាតិ ( បិទរូបថតឯកសណ្ឋាននគរបាលជាតិ ) ។

៤- រាល់សំណើសុំតែងតាំងមុខតំណែងរួមទាំងសំណុំបែបបទត្រូវឆ្លងតាមរយៈនាយកដ្ឋានបុគ្គលិក ដែលជាសេនាធិការធ្វើការពិនិត្យ និងរៀបចំបែបបទតាមនីតិវិធីក្នុងការលើកយោបល់ជូនថ្នាក់ដឹកនាំ តាមឋានានុក្រម ដើម្បីលើកយោបល់ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃពិនិត្យសម្រេច ។

ទទួលបានសេចក្តីណែនាំនេះ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា អគ្គ-នាយកនៃអគ្គនាយកដ្ឋាននានា និងថ្នាក់ប្រហាក់ប្រហែល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋាន-អង្គភាពពាក់ព័ន្ធ និងស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ត្រូវអនុវត្តតាមសេចក្តីណែនាំនេះឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ –

ថ្ងៃ សុក្រ ៩កើត ខែ ផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

ចម្លងជូន៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
(ដើម្បីជូនជ្រាប)
- ឯកសារ-កាលប្បវត្តិ